# តើអ្នកត្រូវការជួយ ពីព្រោះពិការឬ?

**តើវាជាការលំបាកសំរាប់អ្នក ដើម្បីដាក់ពាក្យសុំអត្ថប្រយោជន៍ឬទេ?**
**តើវាជាការលំបាកសំរាប់អ្នក ដើម្បីរក្សាការទទួលអត្ថប្រយោជន៍របស់អ្នកឬទេ?**

ក្រសួងអាចនឹងជួយអ្នកបាន ។ នៅក្រោមច្បាប់មួយហៅថា ក្រឹត្យជនអាមេរិកាំងដែលពិការ (Americans with Disabilities Act - ADA) ក្រសួងអាចផ្តល់ជំនួយបន្ថែមឲ្យអ្នកហៅថា ការសំរបសំរួល ។ ការសំរបសំរួល ADA អាចធ្វើការជាមួយនឹងក្រសួងបានងាយស្រួលឡើង ។

**តើអ្នកណាអាចទទួលការសំរបសំរួលបាន? តើការសំរបសំរួលមានអ្វីខ្លះ?**

បើសិនជាអ្នកមានលក្ខណៈរូបកាយ ឬផ្លូវចិត្ត ដែលធ្វើឲ្យអ្នកលំបាកដើម្បីធ្វើការអ្វីមួយ អ្នកអាចនឹងមានសិទ្ធិទទួលការសំរបសំរួល ADA បាន ។ ឧទាហរណ៍ ៖ បើអ្នកមានលក្ខណៈរូបកាយ ដែលធ្វើឲ្យលំបាលទៅកាន់ការិយាល័យ យើងអាចមកផ្ទះរបស់អ្នកបាន ឬគ្រោងពេលវេលាការណាត់ពេលជួបតាមទូរស័ព្ទ ។

បើអ្នកមានភាពពិការខាងការសិក្សា ដែលធ្វើឲ្យអ្នកលំបាកយល់សំបុត្រស្នាមរបស់ក្រសួង អ្នកកាន់សំណុំរឿងរបស់អ្នកអាចពន្យល់សេចក្តីនោះដល់អ្នក ។
បើវាលំបាកសំរាប់អ្នក ដើម្បីយល់ក្រដាសបំពេញរបស់ក្រសួង អ្នកកាន់សំណុំរឿងរបស់អ្នកអាចជួយអ្នកបំពេញក្រដាសស្នាមទាំងនោះបាន ។ បើអ្នកមានបញ្ហាក្នុងការចងចាំអ្វីៗ យើងអាចធ្វើឲ្យប្រាកដថាអ្នកទទួលសេចក្តីរំលឹក ។ មានការសំរបសំរួលច្រើនប្រភេទ សំរាប់ជួយអ្នក ។

**តើអ្នកទទួលការសំរបសំរួលដោយរបៀបណា? គឺគ្រាន់តែស្នើ!**
បើអ្នកគិតថាអ្នកត្រូវការជំនួយបន្ថែម ត្រូវប្រាប់អ្នកកាន់សំណុំរឿងរបស់អ្នក ។ អ្នកកាន់សំណុំរឿងរបស់អ្នកអាចជួយអ្នកបាន ។ អ្នកកាន់សំណុំរឿងរបស់អ្នក នឹងធ្វើការជាមួយអ្នក និងក្រុមការិយាល័យសំរបសំរួល ADA ដើម្បីលៃលករកមធ្យោបាយដ៏ល្អបំផុត ដើម្បីជួយអ្នក ។

**សមាជិកក្រុមការសំរបសំរួល ADA:**

______________________________________________

បើសិនជាអ្នកពុំបានទទួលជំនួយដែលអ្នកគិតថាអ្នកត្រូវការទេ អ្នកអាចស្នើក្រុមមជ្ឈដ្ឋានការិយាល័យការសំរបសំរួល (Central Office Accommodation Team) ឲ្យពិនិត្យមើលសំណើរបស់អ្នកឡើងវិញ ។ បន្ទាប់ពីការពិនិត្យមើលឡើងវិញនេះមក អ្នកក៏អាចតវ៉ាទៅផ្នែកសវនាការ (Division of Hearings) បានដែរ ។

## ការត្រួតពិនិត្យភាពពិការខាងការសិក្សា ដោយឥតគិតថ្លៃ?
តើអ្នកមានបញ្ហាក្នុងការអាន ការសរសេរ ការចងចាំ ឬការយល់ដឹងអ្វីៗឬទេ? តើការនេះវាធ្វើឲ្យលំបាកសំរាប់អ្នក នៅក្នុងសាលារៀន ឬនៅកន្លែងធ្វើការឬទេ? បើសិនជាដូច្នេះមែន អ្នកប្រហែលជាចង់បានការត្រួតពិនិត្យភាពពិការខាងការសិក្សារបស់ក្រសួងដោយឥតគិតថ្លៃ សំរាប់មនុស្សដែលកំពុងដាក់ពាក្យសុំ ឬកំពុងទទួល TAFDC ។

ការត្រួតពិនិត្យ គឺជាជំហានដំបូងដើម្បីឲ្យអ្នកទទួលជំនួយ ។ បើសិនវាហាក់ដូចជាអ្នកមានភាពពិការខាងការសិក្សា យើងនឹងបង់ថ្លៃសំរាប់ការពិនិត្យមើលឡើងវិញពេញលេញ ។ ការពិនិត្យមើលឡើងវិញនេះក៏ហៅថា ការប្រមាណមើល ដែលរួមមានការសំរបសំរួលសេវា (ការបំរើ) និងការគាំទ្រ ដែលអាចជួយអ្នកឲ្យទៅដល់កន្លែងធ្វើការ ឬគោលដៅការសិក្សារបស់អ្នក ។ **សូមសួរការត្រួតពិនិត្យដោយឥតគិតថ្លៃនៅថ្ងៃនេះ!**

Believing you can. www.mass.gov/dta

OCR-1 Flyer - Khmer (7/2010)
26-414-0710-05